# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## នាយកក្រុមហ៊ុន ថេនថេក អ៊ីនដាសស្ទ្រៀល ខូ អិលធីឌី
## កិច្ចព្រមព្រៀង
### រវាង
### តំណាងរោងចក្រ ភាគី "ក" ជាមួយ ភាគី "ខ" តំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

ឆ្នាំពីរពាន់ម្ភៃ(2020) ខែ តុលា ថ្ងៃទី ៥ វេលាម៉ោង ១០ និង ៣០នាទីថ្ងៃត្រង់នៅការិយាល័យរោងចក្រ **ថេនថេក អ៊ីនដាសស្ទ្រៀល ខូ អិលធីឌី** រវាង តំណាងរោងចក្រ ភាគី "ក" ជាមួយ ភាគី "ខ" តំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន ។ ក្រោយពីបានប្រជុំពិភាក្សា ភាគីទាំងពីរបានយល់ព្រមព្រៀងគ្នាដូចខាងក្រោមៈ

១-ភាគីទាំងពីរបានយល់ព្រមព្យួរការងាររយៈពេល ២ខែ ចំពោះកម្មករ និយោជិតចំនួន **២៧ នាក់** មានផ្នែកដេរ ផ្នែកពិនិត្យគុណភាព ផ្នែកតុកាត់ ផ្នែកវិចខ្ចប់ ផ្នែកជាងម៉ាស៊ីន ផ្នែកអ៊ុត ផ្នែឃ្លាំង ផ្នែកអនាម័យ និងផ្នែកសាប់ ដោយគឺតចាប់ពី **ថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២០** ដោយសាតែអ្នកបញ្ជាទិញផ្អាកការបញ្ជាទិញ ព្រោះប្រទេសទាំងនោះរងផលប៉ះពាល់ពីជម្ងឺរាលកផ្លូវដង្ហើមយ៉ាងធ្ងន់ធ្ងរពី ខូវីដ១៩ (COVID-19) ។

២-ភាគី "ខ" យល់ព្រមទទួលប្រាក់ ឧបត្ថម្ភ **៦០ ដុល្លាអាមេរិក** ពី ភាគី "ក" និង **៨០ ដុល្លាអាមេរិក** ដែលជាប្រាក់ឧបត្ថម្ភពិសេសរបស់រាជរដ្ឋាភិបាល ស្របទៅតាម សេចក្ដីណែនាំរបស់ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ លេខៈ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ស្ដីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប ស ស សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ពីជម្ងឺរាលកផ្លូវដង្ហើមយ៉ាងធ្ងន់ធ្ងរពី ខូវីដ១៩ (COVID-19) ដូច្នេះជាសរុបកម្មករ និយោជិតម្នាក់ៗទទួលបាន **១៤០ ដុល្លាអាមេរិក ក្នុង ២ខែ** សម្រាប់រយៈពេលព្យួរការងារនេះ។

៣-ភាគី "ក" និងបើក **៦០ ដុល្លាអាមេរិក** នេះជូន ភាគី "ខ" **នៅថ្ងៃទី ១២ខែ តុលា ឆ្នាំ២០២០**សម្រាប់រយៈពេល ២ខែនៃព្យួរការងារនេះ(តែមួយលើកប៉ុណ្ណោះ)។

៤-ភាគី "ខ" ត្រូវត្រលប់ចូលធ្វើការវិញនៅ**ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០២០** ក្នុងករណីបងប្អូន កម្មករមិនបានចូលធ្វើការតាមកាលកំណត់នោះទេ រោងចក្រនិងអនុវត្តន៍តាមបទបញ្ជាផ្ទៃក្នុង និងច្បាប់ស្ដីពីការងារ។

កិច្ចព្រមព្រៀងនេះ ចាប់អនុវត្តន៍និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៣រោច ខែ អស្សុជ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

ត្រូវនឹងថ្ងៃទី ៥ ខែ តុលា ឆ្នាំ២០២០

ស្នាមមេដៃតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

១-ឈ្មោះ ប៉ាត់ សូណាត តួនាទី **សហជីពមូលដ្ឋាន** ស្នាមមេ..........

២-ឈ្មោះ ស៊ីម សុខឃាង តួនាទី **ប្រធានផ្នែកដេរ** ស្នាមមេ..........

**នាយកឬតំណាងក្រុមហ៊ុន**

ក្រុមហ៊ុនថេនថេកអ៊ីនដាសស្ទ្រៀល
ផ្នែករដ្ឋបាល
TANTEX INDUSTRIAL CO., LTD.

ស៊ុង ឡេងពន្លៃ

៣-ឈ្មោះ  យ៉ត ស្រីនាត  តួនាទី **ប្រធានក្រុម**  ស្នាមមេ.....................

៤-ឈ្មោះ  គង់ ថេត  តួនាទី **ប្រធានក្រុម**  ស្នាមមេ.....................

៥-ឈ្មោះ  ជឹម ណេង  តួនាទី **ប្រធានក្រុម**  ស្នាមមេ.....................

៦-ឈ្មោះ  អុន សុភ័ស  តួនាទី **ប្រធានក្រុម**  ស្នាមមេ.....................

៧-ឈ្មោះ  មុយ សុខា  តួនាទី **ប្រធានក្រុម**  ស្នាមមេ.....................

៨-ឈ្មោះ  ប្រាក់ បុប្ផា  តួនាទី **ប្រធានក្រុម**  ស្នាមមេ.....................

៩-ឈ្មោះ  អ៊ុំ សុវណ្ណ  តួនាទី **ប្រធានក្រុម**  ស្នាមមេ.....................

១០-ឈ្មោះ  ព្រហ្ម ចិន  តួនាទី **ប្រធានក្រុម**  ស្នាមមេ.....................

១១-ឈ្មោះ  សុន ផៃដែន  តួនាទី **ប្រធានក្រុម**  ស្នាមមេ.....................

១២-ឈ្មោះ  ជួន ចន្ថា  តួនាទី **ប្រធានក្រុម**  ស្នាមមេ.....................